**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០៧៩ សហវ.

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតក្រុមការងារសារពើពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្ត-ទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១**.-

ត្រូវបានបង្កើតក្រុមការងារសារពើពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិត **គង់ វ៉ាវី** | អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តម **ស៊ាង ផល្លា** | អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-លោក **កែន សម្បត្តិ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| ៤-លោក **ផា សេងចេង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធាន |

៥-លោក **សេង តេនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំនៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក

៦-លោក **ណាន សាមឌី** អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម សមាជិក

៧-លោក **បាន ឌី ទិន្ទ** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក

៨-លោក **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិនៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក

៩-លោក **ឈន ទឿន** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១០-លោក **សុខ សុវិទ្យា** ប្រធាននាយកដ្ឋានផែនការនិងបច្ចេកទេសនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១១-លោក **ជា សុភ័ក្ត** ប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១២-លោក **សៀង ស៊ីថា** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក

១៣-លោក **ជា សំណាង** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិនៃអគ្គ-នាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១៤-លោក **ម៉ូក តក្តី** ប្រធានការិយាល័យរដ្ឋបាលនិងគ្រប់គ្រងនៃនាយកដ្ឋានសហ-ប្រតិបត្តិការគយអន្តរជាតិនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១៥-លោក **ម៉ាក់ វិសាល** អនុប្រធានការិយាល័យបច្ចេកទេសគយនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក

១៦-អ្នកស្រីបណ្ឌិត **ខេង្ស រីលីដា** អ្នកស្រាវជ្រាវជាន់ខ្ពស់នៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" សមាជិក

១៧-កញ្ញា **អ៊ីង សុជាតិ** ជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោល-នយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៨-លោក **ចន្លា ម៉េងលី** សេដ្ឋវិទូនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៩-លោក **សុខ សុធារាជ្យ** សេដ្ឋវិទូវ័យក្មេងនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

២០-លោក **គង់ រ៉ាណូ** សេដ្ឋវិទូវ័យក្មេងនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

២១-លោក **ពេជ ចន្ទ្រាថុល** មន្ត្រីបច្ចេកទេសនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" លេខាធិការ។

**ប្រការ២**.-

ក្រុមការងារមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ ថ្លឹងថ្លែង និងវិភាគពីទិដ្ឋភាពផ្សេងៗ ទាំងទិដ្ឋភាពបច្ចេកទេស និងនយោបាយ ដើម្បីកំណត់មូលដ្ឋាន និងវិចារណកម្មច្បាស់លាស់ ក្នុងការឈានទៅរកការកំណត់វិធានការគោលនយោបាយនិងវិធានការ-រដ្ឋបាលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការប្រមូលចំណូលជាតិពីប្រតិបត្តិការធុរកិច្ចនិងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

- សិក្សាស្រាវជ្រាវនូវនិន្នាការតំបន់ និងសកលស្តីពីការគ្រប់គ្រងនិងការប្រមូលចំណូលសារពើពន្ធគ្រប់ប្រភេទពីប្រតិបត្តិការធុរកិច្ច និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- រៀបចំសំណើគោលនយោបាយ និងវិធានការរដ្ឋបាលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការប្រមូលចំណូលជាតិពីប្រតិបត្តិការធុរកិច្ចនិងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ប្រមូល និងវិភាគនូវទិន្នន័យឬស្ថិតិផ្សេងៗដែលពាក់ព័ន្ធ ដើម្បីធ្វើរបាយការណ៍ជាប្រចាំអំពីនិន្នាការនិងស្ថានភាពនៃការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- សិក្សានិងផ្តល់យោបល់លើការកំណត់សមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងក្របខណ្ឌនៃការប្រមូលចំណូលសារពើពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន ( Cross-border e-commerce )
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការកំណត់របស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

ក្រុមការងារមានសិទ្ធិអញ្ជើញមន្ត្រីជំនាញពីក្រសួង-ស្ថាប័នពាក់ព័ន្ធនិងវិស័យឯកជនចូលរួមប្រជុំនិងប្រឹក្សាយោបល់តាមការចាំបាច់។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួន ដូចមាន ចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៧កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ [illegible] ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ